ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៧២៧ ព.ណ សរា.ក

ភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១

## <u>គោរពជូន</u>

## ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានភ្នាក់ងារអនុវត្តគម្រោង១៥ នៃគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម

**<u>កម្មវត្ថុ</u>** : សំណើសុំចាត់បញ្ជូនមន្ត្រីចំនួន**ពីររូប** ចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែ តុលា ឆ្នាំ ២០១១

**<u>យោង</u>** : លិខិតលេខ: ១១៥ សហអ របស់ DICO ចុះថ្ងៃទី ២១ មេសា ២០១១

**<u>ភ្ជាប់ជូន</u>** : របៀបវារៈនៃកិច្ចប្រជុំ

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាតំណាងភ្នាក់ងារអនុវត្តគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម(**TDSP**)មេត្តាជ្រាបថា:ក្រុមការងារ គម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្មនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ(DICO)នៃក្រសួងពាណិជ្ជកម្ម នឹងរៀបចំប្រជុំប្រចាំខែតុលា <u>និងបទបង្ហាញស្តីពី " ការគ្រប់គ្រងបេឡាសាច់ប្រាក់,នីតិវិធីស្នើសុំបុរេប្រទាន,ការជម្រះបញ្ជី និងរបៀបធ្វើផែនការ និងរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃ "</u> ជូនដល់ភ្នាក់ងារអនុវត្តគម្រោង(TDSP)ទាំងអស់។

ដើម្បីជានានូវការអនុវត្តគម្រោងមានប្រសិទ្ធិភាពខ្ពស់ប្រកបដោយតម្លាភាព និងឲ្យបានទាន់ពេលវេលា ខ្ញុំសូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានភ្នាក់ងារអនុវត្តគម្រោង មេត្តាចាត់បញ្ជូនមន្ត្រីបច្ចេកទេសដែលទាក់ទងនិងគម្រោងមកចូលរួមក្នុងកិច្ចប្រជុំនេះដែលនឹងប្រព្រឹត្តិទៅនៅ<u>ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១១ វេលាម៉ោង០៨:០០ **ព្រឹក**</u> នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្ម ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
រដ្ឋលេខាធិការ

ប៉ាន សូរស័ក្តិ

**<u>ចម្លងជូន:</u>**
. ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
. ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ
. ឯកឧត្តម ឌិត ទីណា អនុរដ្ឋលេខាធិការ
. ឯកឧត្តម សុខ សុភ័ក្ត្រ អគ្គនាយកពាណិជ្ជកម្ម
. ឯកសារ កាលប្បវត្តិ